ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

គណៈកម្មាធិការជាតិសម្រាប់ការអភិវឌ្ឍតាមបែប
ប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ (គ.ជ.អ.ប)
លេខាធិការដ្ឋាន
អង្គភាពគ្រប់គ្រង និងគាំទ្រកម្មវិធី
លេខ: ...៣០៤...ស.ប.ស អ.គ.គ.ក

រាជធានីភ្នំពេញ, ថ្ងៃទី..០៦. ខែ..កក្កដា.. ឆ្នាំ២០១៤

**សូមគោរពជូន**
**ឯកឧត្តមប្រធានលេខាធិការដ្ឋាន គ.ជ.អ.ប**

**<u>តាមរយៈ:</u>** ឯកឧត្តមអនុប្រធានប្រតិបត្តិលេខាធិការដ្ឋាន គ.ជ.អ.ប

**<u>កម្មវត្ថុ:</u>** របាយការណ៍សង្ខេបលទ្ធផលការងារកិច្ចការពារសុវត្ថិភាពបរិស្ថាន ដីធ្លីនិងជនជាតិដើមភាគតិច ប្រចាំឆមាសទី១ ឆ្នាំ២០១៤ ។

**<u>យោង:</u>** - សេចក្ដីសម្រេចលេខ ៧៨ សសរ ចុះថ្ងៃទី២៧ ខែសភា ឆ្នាំ២០០៩ ស្ដីពីការបង្កើតក្រុមការងារសុវត្ថិភាពបរិស្ថាន ដីធ្លី និងជនជាតិដើមភាគតិច នៃលេខាធិការដ្ឋាន គ.ជ.អ.ប។
-ផែនការសកម្មភាពរបស់ក្រុមការងារសុវត្ថិភាពបរិស្ថាន ដីធ្លីនិងជនជាតិដើមភាគតិចឆ្នាំ២០១៤

សេចក្ដីដូចមានចែងក្នុងកម្មវត្ថុ និងយោងខាងលើ ខ្ញុំសូមជម្រាបជូនឯកឧត្តម មេត្តាជ្រាបថា កិច្ចការពារសុវត្ថិភាពបរិស្ថាន ដីធ្លី និងជនជាតិដើមភាគតិច ជាកិច្ចការមួយដ៏សំខាន់បំផុតដែលទាមទារនូវការយកចិត្តទុកដាក់ពីគ្រប់អ្នកពាក់ព័ន្ធទាំងអស់នៅថ្នាក់ជាតិ រួមមាន៖ ក្រសួង ស្ថាប័ននានា ក្រុមការងារ និងមន្ត្រីពាក់ព័ន្ធទាំងអស់នៅថ្នាក់ក្រោមជាតិ ព្រមទាំងតម្រូវឲ្យមានការចូលរួមយ៉ាងសកម្មពីសំណាក់ក្រុមប្រឹក្សាឃុំ សង្កាត់ និងការចូលរួមពីប្រជាពលរដ្ឋផងដែរ។ ក្នុងឆមាសទី១ ឆ្នាំ២០១៤នេះ ក្រុមការងារសុវត្ថិភាពបរិស្ថាន ដីធ្លី និងជនជាតិដើមភាគតិច បានខិតខំបំពេញការងារតាមផែនការសកម្មភាពរបស់ខ្លួន ដោយបានយកចិត្តទុកដាក់ និងការទទួលខុសត្រូវខ្ពស់ រហូតទទួលបានលទ្ធផលជាចម្បងៗគួរឲ្យកត់សំគាល់ រួមមានដូចខាងក្រោមនេះ៖

១- បានចុះត្រួតពិនិត្យឯកសាររបាយការណ៍ដីធ្លីរបស់គម្រោងមូលនិធិឃុំ សង្កាត់ឆ្នាំ២០១៣ នៅទីចាត់ការផែនការនិងវិនិយោគខេត្ត និងនៅសាលាឃុំ សង្កាត់ ក្នុងខេត្តចំនួន ០៥ គឺខេត្តបាត់ដំបង ខេត្តប៉ៃលិន ខេត្តកណ្ដាល ខេត្តក្រចេះ និងខេត្តមណ្ឌលគីរី សរុបបានចំនួន ៧៦គម្រោង ស្មើនឹង៦៤% នៃគម្រោងមូលនិធិឃុំសង្កាត់សរុបចំនួន៣៣១គម្រោង ដែលត្រូវការសិក្សាដីធ្លីមានចំនួន១១៨គម្រោងតែប៉ុណ្ណោះ។

២- បានសម្របសម្រួលជាមួយទីប្រឹក្សាគ្រប់គ្រងកម្មវិធីជាតិថ្នាក់ខេត្ត និងមន្ត្រីបង្គោលកិច្ចការពារសុវត្ថិភាពបរិស្ថាន ដីធ្លីនិងជនជាតិដើមភាគតិចខេត្ត រៀបចំបញ្ជីគម្រោងមូលនិធិឃុំ សង្កាត់ដែលបានស្នើឡើងសម្រាប់អនុវត្តឆ្នាំ២០១៤ មានសរុបចំនួន ១៦៦៥ គម្រោង នៃឃុំ សង្កាត់ចំនួន១៥៣៧ ក្នុងនោះរួមមាន៖ តម្រូវការសិក្សាបរិស្ថានចំនួន៦៩៧គម្រោង តម្រូវការសិក្សាដីធ្លីចំនួន ៧៩៨ គម្រោង

និងតម្រូវការសិក្សាកិច្ចការពារសុវត្ថិភាពជនជាតិដើមភាគតិចចំនួន១០៥គម្រោង។គម្រោងមូលនិធិឃុំ សង្កាត់ដែលមានទីតាំងស្ថិតនៅក្នុងតំបន់ឃ្លាំមើលផលប៉ះពាល់បរិស្ថានមានសរុបចំនួន ៥៦៤ គម្រោង និងគម្រោងមូលនិធិឃុំ សង្កាត់ ដែលមានទីតាំងស្ថិតនៅក្នុងបញ្ជីឃ្លាំមើលជនជាតិដើមភាគតិច មាន សរុបចំនួន ១០៥គម្រោង។

៣-បានពិនិត្យនិងផ្តល់យោបល់បច្ចេកទេសឯកសាររបាយការណ៍សុវត្ថិភាពបរិស្ថាននៃគម្រោង មូលនិធិឃុំ សង្កាត់ឆ្នាំ២០១៤ ដែលមានទីតាំងស្ថិតនៅក្នុងតំបន់ឃ្លាំមើលផលប៉ះពាល់បរិស្ថានសរុប ចំនួន ៩២គម្រោង ស្មើនឹង ១៦ ភាគរយ នៃគម្រោងសរុបចំនួន ៥៦៤គម្រោង។

៤-បានពិនិត្យនិងផ្តល់យោបល់បច្ចេកទេសឯកសាររបាយការណ៍សុវត្ថិភាពជនជាតិដើមភាគ តិច នៃគម្រោងមូលនិធិឃុំ សង្កាត់ឆ្នាំ២០១៤ ដែលមានទីតាំងស្ថិតនៅក្នុងតំបន់ឃ្លាំមើលផលប៉ះពាល់ ជនជាតិដើមភាគតិចសរុបចំនួន ៨គម្រោង ស្មើនឹង ៨ភាគរយនៃគម្រោងសរុបចំនួន ១០៥គម្រោង។

៥- បានរៀបចំកិច្ចប្រជុំប្រចាំឆមាសទី១ ឆ្នាំ២០១៤ ស្តីពីការអនុវត្តកិច្ចការពារសុវត្ថិភាពបរិស្ថាន ដីធ្លី និងជនជាតិដើមភាគតិច និងទិសដៅការងារបន្ត ដែលមានអ្នកចូលរួមសរុប ចំនួន៧៩នាក់ ក្នុង នោះមានស្រីចំនួន ០៧នាក់។

តាមរយៈការចុះត្រួតពិនិត្យឯកសាររបាយការណ៍ដីធ្លី និងអនុវត្តការងារជាក់ស្តែង ក្រុមការងារ ពិនិត្យឃើញនូវបញ្ហាប្រឈមមួយចំនួន រួមមានដូចខាងក្រោម៖

១- ខេត្តមួយចំនួនយឺតយ៉ាវក្នុងការផ្ញើឯកសាររបាយការណ៍វិភាគផលប៉ះពាល់បរិស្ថាន និងជន ជាតិដើមភាគតិច មកក្រុមការងារកិច្ចការពារបរិស្ថាន ដីធ្លី និងជនជាតិដើមភាគតិច ។

២- ការបំពេញទម្រង់នានានៅមានភាពខ្វះចន្លោះ ដូចជា មិនចុះកាលបរិច្ឆេទចាប់ផ្តើមអនុវត្ត គម្រោង មិនបានចុះកាលបរិច្ឆេទលើស្នាមផ្តិតមេដៃ ការគូរផែនទីអង្កេតដីធ្លីមិនបានបង្ហាញក្បាលដី ដែលប៉ះពាល់ដោយគម្រោង មិនបានដាក់និមិត្តសញ្ញា។

៣- នៅមានកង្វះខាតនូវការតាមដាន និងគាំទ្រពីសំណាក់មន្ត្រីបច្ចេកទេសហេដ្ឋារចនាសម្ព័ន្ធ ខេត្ត និងមន្ត្រីបច្ចេកទេសគាំទ្រឃុំ សង្កាត់ចំពោះការអនុវត្តកិច្ចការពារសុវត្ថភាពបរិស្ថាន ដីធ្លី និងជន ជាតិដើមភាគតិច ជាពិសេស ក្រុមប្រឹក្សាឃុំ សង្កាត់មិនសូវយកចិត្តទុកដាក់ចំពោះការត្រួតពិនិត្យ គម្រោងរបស់ខ្លួនឲ្យបានដិតដល់ ដែលជាហេតុបណ្តាលឲ្យការអនុវត្តគម្រោងមិនបានត្រឹមត្រូវតាម គោលការណ៍ណែនាំ និងលិខិតបទដ្ឋាននានា។

៤- ខ្វះកិច្ចសហការគ្នារវាងមន្ត្រីគាំទ្រឃុំ សង្កាត់ មន្ត្រីបច្ចេកទេសហេដ្ឋារចនាសម្ព័ន្ធខេត្ត ទីប្រឹក្សាពាក់ព័ន្ធខេត្ត និងខ្វះការតាមដាន ត្រួតពិនិត្យពីសំណាក់មន្ត្រីហេដ្ឋារចនាសម្ព័ន្ធខេត្ត ដែល បណ្តាលឲ្យការអនុវត្តគម្រោងមូលនិធិឃុំសង្កាត់មិនឆ្លើយតបទៅនឹងតម្រូវការជាក់ស្តែងនៅមូលដ្ឋាន។

ដូច្នេះ ដើម្បីដោះស្រាយបញ្ហាប្រឈមទាំងនេះ ទាមទារនូវការយកចិត្តទុកដាក់ពីមន្ត្រីពាក់ព័ន្ធទាំងអស់នៅថ្នាក់ក្រោមជាតិ និងការបង្កើនសមត្ថភាពមន្ត្រីពាក់ព័ន្ធនានា តាមរយៈការបណ្តុះបណ្តាល ការប្រជុំពិភាក្សា ការចុះពិនិត្យឯកសារ និងការចុះពិនិត្យដល់ទីតាំងគម្រោង ព្រមទាំងពង្រឹង និងជំរុញការអនុវត្តកិច្ចការពារសុវត្ថិភាពបរិស្ថាន ដីធ្លី និងជនជាតិដើមភាគតិច នៃគម្រោងមូលនិធិឃុំ សង្កាត់ ក្នុងគោលដៅដើម្បីធានាឲ្យបាននូវការឆ្លើយតបតាមតម្រូវការជាក់ស្តែងនៅមូលដ្ឋាន។

សូមភ្ជាប់មកជាមួយនូវរបាយការណ៍រីកចំរើនប្រចាំឆមាសទី១ ឆ្នាំ២០១៤ ចំនួន ០១ច្បាប់ និងតារាងតាមដាន ត្រួតពិនិត្យ និងផ្តល់យោបល់បច្ចេកទេសគម្រោងមូលនិធិឃុំសង្កាត់ ឆ្នាំ២០១៤ ចំនួន ០១ច្បាប់។

អាស្រ័យដូចបានជម្រាបជូនខាងលើ សូមឯកឧត្តម មេត្តាជ្រាបជាសេចក្តីរាយការណ៍ និងមានមតិណែនាំដ៏ខ្ពង់ខ្ពស់។

សូមឯកឧត្តម មេត្តាទទួលនូវការគោរពដ៏ខ្ពង់ខ្ពស់អំពីខ្ញុំ ។

បានឃើញ និងសូមគោរពជូនឯកឧត្តម
មេត្តាជ្រាបជាសេចក្តីរាយការណ៍។
ប្រធានអង្គភាពគ្រប់គ្រង និងគាំទ្រកម្មវិធី

**នី គីមសាន**

ប្រធានក្រុមការងារ

**ខោល យុទ្ធលី**

បានឃើញ

**ខាំង ចំរើន**

07/07/14

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

លេខាធិការដ្ឋានគណៈកម្មាធិការជាតិសម្រាប់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ

ក្រុមការងារកិច្ចការពារសុវត្ថិភាពបរិស្ថាន ដីធ្លី និងជនជាតិដើមភាគតិច

# របាយការណ៍រីកចំរើន

## ប្រចាំឆមាសទី១ ឆ្នាំ២០១៤



រៀបចំដោយ: ក្រុមការងារកិច្ចការពារសុវត្ថិភាព ប.ដ.ជ នៃលេខាធិដ្ឋាន គ.ជ.អ.ប

ខែមិថុនា ឆ្នាំ២០១៤

**មាតិកា** **########ទំព័រ**

**១.សេចក្តីផ្តើម**........................................................................................................១

**២.សកម្មភាព និងលទ្ធផលសំរេចបាន**..................................................................................១

២.១. ការត្រួតពិនិត្យបញ្ជីគម្រោងមូលនិធិឃុំ សង្កាត់ឆ្នាំ២០១៣ដែលត្រូវការសិក្សាកិច្ចការពារសុវត្ថិភាព..១

២.២. ការពិនិត្យនិងការផ្តល់យោបល់បច្ចេកទេសលើគម្រោងមូលនិធិឃុំ សង្កាត់ឆ្នាំ២០១៤..................២

២.៣. ការត្រួតពិនិត្យឯកសាររបាយការណ៍ដីធ្លីក្រោយពេលដេញថ្លៃឆ្នាំ២០១៣...............................៣

២.៤. ការគាំទ្រ និងកិច្ចសហការ.........................................................................................៣

**៣. បញ្ហាប្រឈមនានា**..........................................................................................................៤

**៤. ការសន្និដ្ឋាន**....................................................................................................................៥

**៥. សំណូមពរ និងអនុសាសន៍**...............................................................................................៦

**៦. សកម្មភាពសំខាន់ៗសម្រាប់ឆមាសទី២ ឆ្នាំ២០១៤**.................................................................៦

## ១. សេចក្តីផ្តើម

នៅក្នុងសៀវភៅភីម កិច្ចការពារសុវត្ថិភាព គឺជាឧបករណ៍សម្រាប់ការពារ**បរិស្ថាន សិទ្ធិក្នុងការប្រើប្រាស់ដីធ្លី** និង**សិទ្ធិរបស់ជនជាតិដើមភាគតិច** ដែលអាចរងឥទ្ធិពលពីគម្រោងមូលនិធិឃុំ សង្កាត់។ គោលបំណងសំខាន់នៃកិច្ចការពារសុវត្ថិភាពទាំងនេះ គឺការជៀសវាង ឬកាត់បន្ថយជាអប្បបរមា ឬក៏សម្រាលបន្ទុកនៃផលប៉ះពាល់ជាអវិជ្ជមានដល់បរិស្ថាន ឬចំណាយសង្គមចំពោះភាគីទី៣ ឬពុំអើពើចំពោះក្រុមជនងាយរងគ្រោះ ដែលអាចទទួលរងឥទ្ធិពលពីគម្រោងអភិវឌ្ឍន៍ឃុំ សង្កាត់។

កិច្ចការពារសុវត្ថិភាពបរិស្ថាន ដីធ្លី និងជនជាតិដើមភាគតិច បានក្លាយជាប្រធានបទមួយយ៉ាងសំខាន់សម្រាប់ការអនុវត្តគម្រោងមូលនិធិឃុំ សង្កាត់។ លេខាធិការដ្ឋាន គ.ជ.អ.ប បានពិចារណាយ៉ាងល្អិតល្អន់លើដំណោះស្រាយបញ្ហាបរិស្ថាន ដីធ្លី និងជនជាតិដើមភាគតិច ជាអាទិភាពសម្រាប់គ្រប់គម្រោងអភិវឌ្ឍន៍ឃុំ សង្កាត់ ទោះបីរាជរដ្ឋាភិបាលកម្ពុជា ពុំបានទទួលជំនួយពីធនាគារពិភពលោក ដើម្បីគាំទ្រដល់ការអនុវត្តគម្រោងវិនិយោគជនបទ និងអភិបាលកិច្ចមូលដ្ឋានយ៉ាងណាក៏ដោយ។

គោលការណ៍ណែនាំអនុវត្តកិច្ចការពារសុវត្ថិភាពបរិស្ថាន គឺជាផ្នែកមួយយ៉ាងសំខាន់ដែលមានចែងក្នុងសៀវភៅណែនាំស្តីពីការអនុវត្តគម្រោងមូលនិធិឃុំ សង្កាត់(ភីម)។ ចាប់តាំងពីមានការត្រួតពិនិត្យការអនុវត្តកិច្ចការពារសុវត្ថិភាពទាំងបី (បរិស្ថាន ដីធ្លី និងជនជាតិដើមភាគតិច) ឱ្យស្របតាមគោលការណ៍ណែនាំដែលបានយល់ព្រមដោយលេខាធិការដ្ឋាន គ.ជ.អ.ប និងម្ចាស់ជំនួយ។ លេខាធិការដ្ឋាន គ.ជ.អ.ប បានបង្កើតក្រុមការងារសុវត្ថិភាពបរិស្ថាន ដីធ្លី និងជនជាតិដើមភាគតិច កាលពីថ្ងៃទី២៧ ខែឧសភា ឆ្នាំ២០០៩ ដើម្បីពិនិត្យ និងផ្តល់យោបល់ទៅលើៈ ១)-ដំណើរការនៃសិក្សាផលប៉ះពាល់បរិស្ថាន ដីធ្លី និងជនជាតិដើមភាគតិច និង២)-របាយការណ៍វិភាគផលប៉ះពាល់បរិស្ថាន ការរៀបចំសិក្សាលទ្ធកម្មដីធ្លី និងវិធានការការពារសុវត្ថិភាពជនជាតិដើមភាគតិច និងការសម្របសម្រួលជាមួយអ្នកពាក់ព័ន្ធនានាក្នុងការអនុវត្តកិច្ចការពារសុវត្ថិភាពឱ្យមានប្រសិទ្ធភាព។

ក្នុងឆមាសទី១ ឆ្នាំ២០១៤ ក្រុមការងារបានអនុវត្តសកម្មភាព និងសំរេចបានលទ្ធផលចម្បងៗមួយចំនួនដូចជា ការផ្តល់យោបល់បច្ចេកទេសលើឯកសាររបាយការណ៍បរិស្ថាន និងជនជាតិដើមភាគតិច និងចុះពង្រឹងការអនុវត្តកិច្ចការពារសុវត្ថិភាពបរិស្ថាន ដីធ្លី និងជនជាតិដើមភាគតិច ជាក់ស្តែងនៅតាមបណ្តាឃុំ សង្កាត់ និងទីតាំងគម្រោង ដោយបានជួបជាមួយមន្ត្រីពាក់ព័ន្ធ ទីប្រឹក្សាក្រុង ស្រុក ខេត្ត ក្រុមប្រឹក្សាឃុំ សង្កាត់ និងប្រជាពលរដ្ឋ ដែលជាអ្នកទទួលផលពីគម្រោង។ លើសពីនេះ ក្រុមការងារបានសម្របសម្រួលជាមួយទីប្រឹក្សាគ្រប់គ្រងកម្មវិធីជាតិថ្នាក់ខេត្ត និងមន្ត្រី បង្គោលកិច្ចការពារសុវត្ថិភាពបរិស្ថាន ដីធ្លី និងជនជាតិដើមភាគតិចខេត្ត ដើម្បីរៀបចំបញ្ជីគម្រោងមូលនិធិឃុំ សង្កាត់ ឆ្នាំ២០១៤ ដែលត្រូវការសិក្សាកិច្ចការពារសុវត្ថិភាពបរិស្ថាន ដីធ្លី និងជនជាតិដើមភាគតិច។

## ២. សកម្មភាព និងលទ្ធផលសំរេចបាន

### ២.១. ការផ្ទៀងផ្ទាត់ និងបូកសរុបបញ្ជីគម្រោងមូលនិធិឃុំ សង្កាត់ ឆ្នាំ២០១៤ ដែលត្រូវការសិក្សាបរិស្ថាន ដីធ្លី និងជនជាតិដើមភាគតិចៈ

គម្រោងមូលនិធិឃុំ សង្កាត់ដែលត្រូវបានស្នើឡើងសម្រាប់អនុវត្តនៅឆ្នាំ២០១៤សរុបចំនួន **១.៦៦៥** គម្រោង នៃ**១.៩៣៧**ឃុំ សង្កាត់ ក្នុងនោះ រួមមានៈ តម្រូវការសិក្សាបរិស្ថានសរុបចំនួន **៦៩៧**គម្រោង ត្រូវការសិក្សាដីធ្លីសរុបចំនួន **៧៤៨**គម្រោង និងតម្រូវការសិក្សាកិច្ចការពារសុវត្ថិភាពជនជាតិដើមភាគតិច សរុបចំនួន **១០៥** គម្រោង។ គម្រោងមូលនិធិឃុំ សង្កាត់ ដែលមានទីតាំងស្ថិតនៅក្នុងតំបន់ឃ្លាំមើលផលប៉ះពាល់បរិស្ថាន សរុបចំនួន **៥៦៤**គម្រោង និងគម្រោងមូលនិធិឃុំសង្កាត់ដែលមានទីតាំងស្ថិតនៅក្នុងបញ្ជីឃ្លាំមើលជនជាតិដើមភាគតិច សរុបចំនួន **១០៥**គម្រោង

ដែលទីចាត់ការផែនការ និងវិនិយោគខេត្ត ត្រូវផ្ញើរបាយការណ៍ទាំងនោះមកក្រុមការងារដើម្បីពិនិត្យ និងផ្តល់យោបល់បច្ចេកទេស ។




ដើម្បីពិនិត្យ និងផ្តល់យោបល់បច្ចេកទេសពីភាពត្រឹមត្រូវមុននឹងអនុញ្ញាតឱ្យដំណើរការដេញថ្លៃគម្រោង *(តារាងលំអិតមានភ្ជាប់មកជាមួយនូវឧបសម្ព័ន្ធ៧.១)*។ ក្រាហ្វិចខាងក្រោមបង្ហាញពីចំនួនគម្រោងមូលនិធិឃុំ សង្កាត់ ដែលត្រូវបានស្នើឡើងនៅតាមបណ្តាខេត្តទាំង២៣ក្នុងតំបន់ទាំងពីរ៖

**២.២. ការពិនិត្យ និងការផ្តល់យោបល់បច្ចេកទេសលើគម្រោងមូលនិធិឃុំ សង្កាត់ឆ្នាំ២០១៤៖**

បានពិនិត្យ និងផ្តល់យោបល់បច្ចេកទេសឯកសាររបាយការណ៍សុវត្ថិភាពបរិស្ថានស្ថិតក្នុងឃុំ សង្កាត់ឃ្លាំមើលផលប៉ះពាល់បរិស្ថានសរុបចំនួន **៩២**គម្រោង ស្មើនឹង**១៦%**នៃគម្រោងស្ថិតក្នុងបញ្ជីឃ្លាំមើលសរុបចំនួន**៥៦៤**គម្រោង និងផ្តល់យោបល់បច្ចេកទេសរបាយការណ៍កិច្ចការពារសុវត្ថិភាពជនជាតិដើមភាគតិចសរុបចំនួន **៨**គម្រោង ស្មើនឹង**៨%**នៃចំនួនសរុប**១០៥**គម្រោង ដែលស្ថិតក្នុងបញ្ជីឃ្លាំមើលជនជាតិដើមភាគតិច *(តារាងលំអិតមានភ្ជាប់មកជាមួយនូវឧបសម្ព័ន្ធ៧.២)* ។ ក្រាហ្វិចខាងក្រោមបង្ហាញចំនួនគម្រោង ដែលបានផ្តល់យោបល់បច្ចេកទេស៖



## ២.៣. ការត្រួតពិនិត្យឯកសាររបាយការណ៍ដីធ្លីក្រោយពេលដេញថ្លៃគម្រោងឆ្នាំ២០១៣៖

បានចុះត្រួតពិនិត្យឯកសាររបាយការណ៍ដីធ្លីនៅទីចាត់ការផែនការ និងវិនិយោគខេត្ត និងឃុំ សង្កាត់សរុបចំនួន **៧៦**គម្រោងស្មើនឹង**៦៤%**នៃគម្រោងមូលនិធិឃុំសង្កាត់សរុបចំនួន**៣៣១**គម្រោង ត្រូវការសិក្សាដីធ្លីសរុបចំនួន **១១៨** គម្រោង។ ដំណើរការនៃការត្រួតពិនិត្យរបាយការណ៍នេះ ធ្វើនៅទីចាត់ការផែនការ និងវិនិយោគខេត្ត និងសាលាឃុំ សង្កាត់ ហើយបានផ្ទៀងផ្ទាត់របាយការណ៍ទាំងនោះ នៅតាមទីតាំងគម្រោង ដោយជួបជាមួយអ្នកទទួលផលពីគម្រោង។ បន្ទាប់ពីបញ្ចប់ រាល់ការពិនិត្យឯកសារ ក្រុមការងារបានបង្ហាញពីលទ្ធផលដែលបានរកឃើញដល់នាយក នាយករងរដ្ឋបាលសាលាខេត្ត នាយក នាយករងទីចាត់ការផែនការ និងវិនិយោគខេត្ត ទីប្រឹក្សាគ្រប់គ្រងកម្មវិធីជាតិថ្នាក់ខេត្ត ទីប្រឹក្សាខេត្តពាក់ព័ន្ធ ទីប្រឹក្សាស្រុក ក្រុង ដើម្បីផ្តល់យោបល់លើចំណុចខ្វះខាត ជាមេរៀនពិសោធន៍សម្រាប់អនុវត្តនៅឆ្នាំក្រោយៗទៀត។ តារាងខាងក្រោម បង្ហាញពី ចំនួនឯកសាររបាយការណ៍ដីធ្លី ដែលក្រុមការងារបានត្រួតពិនិត្យ៖

| ល.រ | ឈ្មោះខេត្ត | ចំនួនគម្រោង | ចំនួនគម្រោងត្រូវការសិក្សាដីធ្លី | ចំនួនគម្រោងបានពិនិត្យ | ចំនួន% |
|---|---|---|---|---|---|
| ១ | បាត់ដំបង | ១១៣ | ២០ | ១៨ | ៩០% |
| ២ | ប៉ៃលិន | ៩ | ៧ | ៧ | ១០០% |
| ៣ | កណ្តាល | ១៤១ | ៥៩ | ២៩ | ៤៩% |
| ៤ | ក្រចេះ | ៤៦ | ២៩ | ១៩ | ៦៦% |
| ៥ | មណ្ឌលគិរី | ២២ | ៣ | ៣ | ១០០% |
| **សរុប** | | **៣៣១** | **១១៨** | **៧៦** | **៦៤%** |

## ២.៤. ការគាំទ្រ និងកិច្ចសហការ៖

- ក្រុមការងារបានជួយសម្របសម្រួលជាមួយទីប្រឹក្សាគ្រប់គ្រងកម្មវិធីជាតិថ្នាក់ខេត្តដើម្បីពន្លឿនការសិក្សាកិច្ចការពារសុវត្ថិភាពទាំងបី ដើម្បីផ្ញើឯកសាររបាយការណ៍វិភាគផលប៉ះពាល់បរិស្ថាន និងជនជាតិដើមភាគតិច មកក្រុមការងារកិច្ចការពារបរិស្ថាន ដីធ្លី និងជនជាតិដើមភាគតិច ដើម្បីពិនិត្យ និងផ្តល់យោបល់បច្ចេកទេសគម្រោងឱ្យទាន់ពេលវេលានិងឆ្លើយតបតាមតម្រូវការជាក់ស្តែងនៅមូលដ្ឋាន
- ក្រុមការងារបានជួយអនុកម្មវិធីទី២ ក្នុងការរៀបចំសៀវភៅគោលការណ៍ណែនាំ ស្តីពីការរៀបចំគម្រោងមូលនិធិក្រុង ស្រុក ដូចជា ជួយផ្តល់យោបល់ដើម្បីកែតម្រូវនូវចំណុចខ្វះចន្លោះនៅក្នុងផ្នែកគោលនយោបាយស្តីពីកិច្ចការពារសុវត្ថិភាពបរិស្ថាន ដីធ្លី និងជនជាតិដើមភាគតិច ជួយសម្របសម្រួលសិក្ខាសាលាពិគ្រោះយោបល់អំពីសៀវភៅណែនាំស្តីពីការរៀបចំគម្រោងក្រុង ស្រុក នៅខេត្តព្រះសីហនុ ព្រមទាំងបានជួយសម្របសម្រួលក្នុងវគ្គបណ្តុះបណ្តាលសាកល្បងស្តីពីការរៀបចំគម្រោងក្រុង ស្រុក ដល់គ្រូឧទ្ទេសថ្នាក់ជាតិ នៅខេត្តបាត់ដំបង។
- ក្រុមការងារបានជួយអនុកម្មវិធីទី២ ក្នុងការរៀបចំសៀវភៅគោលការណ៍ណែនាំ ស្តីពីការរៀបចំគម្រោងមូលនិធិរាជធានី ខេត្ត ដូចជា ជួយផ្តល់យោបល់ដើម្បីកែតម្រូវនូវចំណុចខ្វះចន្លោះនៅក្នុងផ្នែកគោលនយោបាយស្តីពីកិច្ចការពារសុវត្ថិភាពបរិស្ថាន ដីធ្លី និងជនជាតិដើមភាគតិច ជួយសម្របសម្រួលសិក្ខាសាលាពិគ្រោះយោបល់អំពីសៀវភៅណែនាំ ស្តីពីការរៀបចំគម្រោងរាជធានី ខេត្ត នៅខេត្តព្រះ

សីហនុ ព្រមទាំងបានជួយសម្របសម្រួលក្នុងវគ្គបណ្តុះបណ្តាលសាកល្បង ស្តីពីការរៀបចំគម្រោងរាជធានី ខេត្តដល់គ្រូឧទ្ទេសថ្នាក់ជាតិ នៅខេត្តព្រះសីហនុ។

- ក្រុមការងារបានការរៀបចំកិច្ចប្រជុំប្រចាំឆមាសទី១ ឆ្នាំ២០១៤ ស្តីពីការអនុវត្តកិច្ចការពារសុវត្ថិភាពបរិស្ថាន ដីធ្លី និងជនជាតិដើមភាគតិច មានសមាជិក សមាជិកា ចូលរួមសរុបប្រមាណ៧៩រូប ស្រី ៧រូប ដែលអញ្ជើញចូលរួម ដោយនាយក ឬនាយករងរដ្ឋបាលសាលាខេត្ត នាយក ឬនាយករងទីចាត់ការផែនការនិងវិនិយោគខេត្ត និងមន្ត្រីបង្គោលកិច្ចការពារសុវត្ថិភាពបរិស្ថាន ដីធ្លី និងជនជាតិដើមភាគតិច មន្ត្រីក្រុមការងារនៃលេខាធិការដ្ឋាន គ.ជ.អ.ប ទីប្រឹក្សាសុវត្ថិភាព ទីប្រឹក្សាមកពីអនុកម្មវិធីទី២ និងទីប្រឹក្សាអភិវឌ្ឍន៍សមត្ថភាពខេត្តមួយចំនួន។

## ៣. បញ្ហាប្រឈមនានា

- ខេត្តមួយចំនួនមានការយឺតយ៉ាវក្នុងការផ្ញើឯកសាររបាយការណ៍វិភាគផលប៉ះពាល់បរិស្ថាន និងជនជាតិដើមភាគតិច មកក្រុមការងារកិច្ចការពារសុវត្ថិភាពបរិស្ថាន ដីធ្លី និងជនជាតិដើមភាគតិច។
- ការអនុវត្តគម្រោងមូលនិធិឃុំ សង្កាត់មួយចំនួននៅមានភាពខ្វះចន្លោះច្រើន ដូចជា គម្រោងខ្លះត្រូវការសិក្សាដីធ្លី តែបែរជាមិនសិក្សាដីធ្លីទៅវិញ ការបំពេញទម្រង់នានានៅមានភាពខ្វះចន្លោះ ដូចជា មិនចុះកាលបរិច្ឆេទចាប់ផ្តើមអនុវត្តគម្រោង មិនបានចុះកាលបរិច្ឆេទលើស្នាមផ្តិតមេដៃ ការគូរផែនទីអង្កេតដីធ្លីមិនបានបង្ហាញក្បាលដីដែលប៉ះពាល់ដោយគម្រោង មិនបានដាក់និមិត្តសញ្ញា ព្រមទាំងមិនមានកំណត់ហេតុប្រជុំទៀត។ គម្រោងមួយចំនួនត្រូវរៀបចំរបាយការណ៍លទ្ធកម្មដីធ្លី (ទូទាត់សំណង) ប៉ុន្តែ គម្រោងទាំងនោះ បែរជារៀបចំរបាយការណ៍បរិច្ចាគដីធ្លីដោយស្ម័គ្រចិត្តទៅវិញ ឯកសារគម្រោងច្បាប់ដើមមិនបានរក្សាទុកនៅសាលាឃុំសង្កាត់ មានស្នាមផ្តិតមេដៃជំនួសនៅទម្រង់ទី២០.៥ ការចុះអង្កេតដីធ្លីមុនការប្រជុំផ្សព្វផ្សាយអំពីសិទ្ធិរបស់កម្មសិទ្ធិករ ឬភោគី ឬអ្នកប្រើប្រាស់ដីធ្លី(ប្រជុំលើកទី១) មិនចុះកាលបរិច្ឆេទអនុវត្តគម្រោង ។
- កង្វះកិច្ចសហការគ្នារវាងមន្ត្រីបច្ចេកទេសគាំទ្រឃុំ សង្កាត់ មន្ត្រីបច្ចេកទេសហេដ្ឋារចនាសម្ព័ន្ធខេត្ត ទីប្រឹក្សាពាក់ព័ន្ធ ខ្វះការតាមដាន និងត្រួតពិនិត្យពីសំណាក់មន្ត្រីហេដ្ឋារចនាសម្ព័ន្ធខេត្តដែលបណ្តាលឱ្យការអនុវត្តគម្រោងមូលនិធិឃុំ សង្កាត់ មិនឆ្លើយតបទៅនឹងតម្រូវការជាក់ស្តែងនៅមូលដ្ឋាន។
- ការសិក្សាគម្រោងនៅមានភាពមិនច្បាស់លាស់ ជាពិសេស ការសិក្សាដីធ្លី ព្រោះពិនិត្យឃើញមានលិខិតបញ្ជាក់អះអាងថា ដីសាធារណៈរបស់ឃុំផង និងមានរបាយការណ៍សិក្សាដីធ្លីផង។
- ការរៀបចំទុកដាក់ឯកសារគម្រោងរបស់ខេត្ត ពុំមានសណ្តាប់ធ្នាប់(មិនតាមលំដាប់លំដោយ)។
- នៅមានកង្វះខាតនូវការតាមដាន និងគាំទ្រពីសំណាក់មន្ត្រីបច្ចេកទេសហេដ្ឋារចនាសម្ព័ន្ធខេត្ត និង មន្ត្រីបច្ចេកទេសគាំទ្រឃុំ សង្កាត់ចំពោះការអនុវត្តកិច្ចការពារសុវត្ថភាពបរិស្ថាន ដីធ្លី និងជនជាតិដើមភាគតិច ជាពិសេស ក្រុមប្រឹក្សាឃុំ សង្កាត់មិនសូវយកចិត្តទុកដាក់ចំពោះការត្រួតពិនិត្យគម្រោងរបស់ខ្លួនឱ្យបានដិតដល់ដែលជាហេតុបណ្តាលឱ្យការអនុវត្តគម្រោងមិនបានត្រឹមត្រូវតាមគោលការណ៍ណែនាំ និងលិខិតបទដ្ឋាននានា។

## ៤. ការសន្និដ្ឋាន

ពិនិត្យជារួម ក្នុងឆមាសទី១ ឆ្នាំ២០១៤នេះ ក្រុមការងារបានអនុវត្តសកម្មភាពស្របទៅតាមផែនការសកម្មភាពដែលបានគ្រោងទុក ទាំងការត្រួតពិនិត្យឯកសាររបាយការណ៍ និងការផ្តល់យោបល់លើការអនុវត្តសុវត្ថិភាពបរិស្ថាន ដីធ្លី និងជនជាតិដើមភាគតិចក្នុងក្របខណ្ឌគម្រោងមូលនិធិឃុំ សង្កាត់ ទោះបីមានការយឺតយ៉ាវក្នុងការសិក្សាគម្រោងទាំងនោះយ៉ាងណាក៏ដោយ។ តាមរយៈការចុះត្រួតពិនិត្យឯកសាររបាយការណ៍ដីធ្លី ជួបជាមួយអ្នកពាក់ព័ន្ធ និងការចុះអង្កេតផ្ទាល់ ពិនិត្យឃើញថា ការរៀបចំឯកសារ និងការអនុវត្តគម្រោងមូលនិធិឃុំ សង្កាត់ឆ្នាំ២០១៣ ទាក់ទងនឹងដីធ្លីមានលក្ខណៈល្អបង្គួរ បើប្រៀបធៀបទៅនឹងឯកសាររបាយការណ៍សុវត្ថិភាពដីធ្លីនៃការអនុវត្តគម្រោងមូលនិធិឃុំ សង្កាត់ឆ្នាំ២០១២។ ទន្ទឹម នឹងលក្ខណៈល្អបង្គួរនេះ ក្រុមការងារបានសង្កេតឃើញ នៅមានឃុំ សង្កាត់មួយចំនួនបំពេញទម្រង់នានានៅមានភាពខ្វះចន្លោះ ដូចជា មិនបំពេញកាលបរិច្ឆេទបញ្ចប់ការសិក្សាគម្រោង មិនបានបញ្ជាក់និងប្រថាប់ត្រាឃុំនៅគ្រប់សន្លឹកក្នុងទម្រង់ទី២០.៥ ព្រមទាំងផ្តិតមេដៃខុសកូឡោនក្នុងទម្រង់ទី២០.៥ និងការគូរផែនទីអង្កេតដីធ្លីមិនបានបង្ហាញក្បាលដីនីមួយៗ ដែលប៉ះពាល់ដោយសារការអនុវត្តគម្រោង។ ជាមួយគ្នានឹងការបំពេញឯកសារខ្វះចន្លោះនេះ ខេត្តនីមួយៗជួបនូវបញ្ហាមួយចំនួន ដូចជា ខ្វះឧបករណ៍បច្ចេកទេសប្រើប្រាស់ ខ្វះមន្ត្រីបច្ចេកទេសគាំទ្រឃុំ សង្កាត់ និងខ្វះកិច្ចសហការពីមន្ទីរអភិវឌ្ឍន៍ជនបទ។ ដូច្នេះ ដើម្បីពង្រឹងការអនុវត្តសកម្មភាពកិច្ចការពារសុវត្ថិភាពទាំងបី ជាពិសេស កិច្ចការពារសុវត្ថិភាពដីធ្លីនៃគម្រោងមូលនិធិឃុំ សង្កាត់ឱ្យបានឆ្លើយតបតាមគោលការណ៍ណែនាំដូចមានចែងក្នុងសៀវភៅភីម និងលិខិតណែនាំនានា លុះត្រាតែមានប្តេជ្ញាចិត្ត និងការយកចិត្តទុកដាក់ពីមន្ត្រី និងទីប្រឹក្សា ពាក់ព័ន្ធ ជាពិសេស ការផ្តោតជាសំខាន់លើការតាមដាន ការត្រួតពិនិត្យពីសំណាក់ទីប្រឹក្សាហេដ្ឋារចនាសម្ព័ន្ធខេត្ត និងទីប្រឹក្សាកសាងនិងអភិវឌ្ឍន៍សមត្ថភាពខេត្ត ទាំងការរៀបចំទុកដាក់ឯកសារ និងការអនុវត្តជាក់ស្តែង ព្រមទាំងផ្តល់ការហ្វឹកហ្វឺនបន្ថែមដល់ទីប្រឹក្សាក្រុង ទីប្រឹក្សាស្រុក មន្ត្រីបច្ចេកទេសគាំទ្រឃុំ សង្កាត់ និងមន្ត្រីបច្ចេកទេសហេដ្ឋារចនាសម្ព័ន្ធ។

## ៥. សំណូមពរ និងអនុសាសន៍

- ពង្រឹងការអនុវត្តសកម្មភាពកិច្ចការពារសុវត្ថិភាពទាំងបី ជាពិសេស កិច្ចការពារសុវត្ថិភាពដីធ្លី នៃគម្រោងមូលនិធិឃុំ សង្កាត់ និងដើម្បីឆ្លើយតបតាមគោលការណ៍ណែនាំ ដូចមានចែងក្នុងសៀវភៅភីម និងលិខិតណែនាំនានា លុះត្រាតែបង្កើនការយកចិត្តទុកដាក់ពីមន្ត្រី និងទីប្រឹក្សាពាក់ព័ន្ធ ជាពិសេស ការតាមដាន ត្រួតពិនិត្យពីសំណាក់ទីប្រឹក្សាហេដ្ឋារចនាសម្ព័ន្ធខេត្ត និងទីប្រឹក្សាពង្រឹងសមត្ថភាព ទាំងការរៀបចំទុកដាក់ឯកសារ និងការអនុវត្តជាក់ស្តែង ព្រមទាំងផ្តល់ការហ្វឹកហ្វឺនបន្ថែមដល់ទីប្រឹក្សាក្រុង ស្រុក មន្ត្រីបច្ចេកទេសគាំទ្រឃុំ សង្កាត់ និងមន្ត្រីបច្ចេកទេសហេដ្ឋារចនាសម្ព័ន្ធខេត្ត។
- មន្ត្រីបច្ចេកទេសហេដ្ឋរចនាសម្ពន្ធ័ខេត្ត ត្រូវជួយគាំទ្រឃុំ សង្កាត់ ក្នុងការសិក្សាគម្រោងឱ្យបានត្រឹមត្រូវតាមគោលការណ៍ណែនាំក្នុងសៀវភៅភីម និងលិខិតណែនាំនានា ។
- ក្រុមប្រឹក្សាឃុំ សង្កាត់ ត្រូវបង្កើនការយកចិត្តទុកដាក់ចំពោះការសិក្សារៀបចំឯកសារគម្រោងឱ្យបានត្រឹមត្រូវ តាមគោលការណ៍ណែនាំ ព្រមទាំងបង្កើនការត្រួតពិនិត្យ និងការតាមដានការអនុវត្តគម្រោងរបស់ខ្លួនឱ្យបានជិតដល់។
- មន្ត្រីពាក់ពន្ធ័ខេត្ត ទីប្រឹក្សាខេត្ត ទីប្រឹក្សាក្រុង និងទីប្រឹក្សាស្រុក ត្រូវជួយជំរុញក្រុមប្រឹក្សាឃុំ សង្កាត់ បង្កើនការផ្សព្វផ្សាយអំពីសេចក្តីប្រកាសអំពីសិទ្ធិរបស់កម្មសិទ្ធិករ ឬភោគី ឬអ្នកប្រើប្រាស់ដីធ្លី (ទម្រង់ទី១៩) ឱ្យបានទូលំទូលាយ ។
- មន្ត្រីបច្ចេកទេសគាំទ្រឃុំ សង្កាត់ត្រូវខិតខំស្វែងយល់លើការងារសុវត្ថិភាពបរិស្ថាន ដីធ្លីនិងជនជាតិដើមភាគតិច បន្ថែមលើតួនាទី ភារកិច្ចរបស់ខ្លួន ដែលមានស្រាប់ ដើម្បីជួយគាំទ្រឃុំ សង្កាត់ក្នុងការរៀបចំឯកសារគម្រោងឱ្យបាន ត្រឹមត្រូវ ក៏ដូចជា បង្កើនសមត្ថភាពផ្ទាល់ខ្លួនផងដែរ។

- ខេត្តគួរមានការប្រជុំពិភាក្សាលម្អិតអំពីការសិក្សាគម្រោងមូលនិធិឃុំ សង្កាត់ជាមួយមន្ទីរវិស័យ ដោយមានការគាំទ្រពីក្រុមប្រឹក្សាខេត្ត និងគណៈអភិបាលខេត្ត។

## ៦. សកម្មភាពសំខាន់ៗសម្រាប់ឆមាសទី២ ឆ្នាំ២០១៤

- បន្តពិនិត្យ និងផ្តល់យោបល់កែតម្រូវបច្ចេកទេសលើឯកសាររបាយការណ៍សុវត្ថិភាពជនជាតិដើមភាគតិច និងឯកសាររបាយការណ៍កិច្ចការពារសុវត្ថិភាពបរិស្ថាននៃគម្រោងមូលនិធិឃុំ សង្កាត់។

-សម្របសម្រួលជាមួយអនុកម្មវិធីទី២ ក្នុងការរៀបចំសៀវភៅគោលការណ៍ណែនាំ ស្តីពីការរៀបចំ គម្រោងមូលនិធិរាជធានី ខេត្ត ដើម្បីបណ្តុះបណ្តាលដល់មន្ត្រី និងទីប្រឹក្សាពាក់ព័ន្ធនៅថ្នាក់ក្រោមជាតិ។

- ចុះត្រួតពិនិត្យឯកសាររបាយការណ៍ដីធ្លីនៃការអនុវត្តគម្រោងមូលនិធិឃុំ សង្កាត់ឆ្នាំ២០១៤។

- សម្របសម្រួលជាមួយការិយាល័យពាក់ព័ន្ធនៃអង្គភាពគ្រប់គ្រង និងគាំទ្រកម្មវិធី និងទីប្រឹក្សាពាក់ព័ន្ធថ្នាក់ជាតិដើម្បីរៀបចំផែនការសកម្មភាព និងថវិកាសម្រាប់ឆ្នាំ២០១៥ ក្នុងគោលដៅដើម្បីគាំទ្រដល់ការអនុវត្តសកម្មកិច្ចការពារសុវត្ថិភាពទាំងបី។

- រៀបចំរបាយការណ៍រីកចំរើនប្រចាំឆ្នាំ២០១៤ ដាក់ជូនលេខាធិការដ្ឋាន គ.ជ.អ.ប។

- រៀបចំកិច្ចប្រជុំប្រចាំឆ្នាំ២០១៤ស្តីពីការអនុវត្តកិច្ចការពារសុវត្ថិភាពបរិស្ថាន ដីធ្លី និងជនជាតិដើមភាគតិចក្នុងក្របខ័ណ្ឌគម្រោងមូលនិធិឃុំ សង្កាត់។

**រៀបចំដោយ**

**ក្រុមការងារកិច្ចការពារសុវត្ថិភាព**

**លេខាធិការដ្ឋាន គ.ជ.អ.ប**

តារាងតាមដាន ត្រួតពិនិត្យ និងផ្តល់យោបល់បច្ចេកទេសគម្រោងមូលនិធិឃុំ សង្កាត់ឆ្នាំ២០១៤(១២ មិថុនា ឆ្នាំ២០១៤)

| # | កូដខេត្ត | ឈ្មោះខេត្ត | ចំនួនឃុំ សង្កាត់ | ចំនួនគម្រោង ២០១៤ | ចំនួនគម្រោងមានតម្រូវការសុវត្ថិភាព | | | ចំនួនគម្រោងក្នុងបញ្ជីឃ្លាំមើល | | ចំនួនគម្រោងផ្តល់យោបល់បច្ចេកទេស | | %បានផ្តល់យោបល់បច្ចេកទេស | |
|---|---|---|---|---|---|---|---|---|---|---|---|---|---|
| | | | | | បរិស្ថាន | ដីធ្លី | ជនជាតិ | បរិស្ថាន | ជនជាតិ | បរិស្ថាន | ជនជាតិ | បរិស្ថាន | ជនជាតិ |
| 1 | 4 | កំពង់ឆ្នាំង | 69 | **70** | **31** | 48 | **0** | 24 | **0** | 17 | 0 | 71% | #DIV/0! |
| 2 | 5 | កំពង់ស្ពឺ | 87 | 87 | 18 | 30 | **0** | 18 | **0** | 15 | 0 | 83% | #DIV/0! |
| 3 | 8 | កណ្តាល | 127 | 144 | 9 | 60 | **0** | 5 | **0** | 4 | 0 | 80% | #DIV/0! |
| 4 | 14 | ព្រៃវែង | 116 | 124 | 3 | 60 | **0** | 3 | **0** | 3 | 0 | 100% | #DIV/0! |
| 5 | 20 | ស្វាយរៀង | 80 | 85 | 3 | 38 | **0** | 2 | **0** | 2 | 0 | 100% | #DIV/0! |
| 6 | 21 | តាកែវ | 100 | 110 | 12 | 78 | **0** | 12 | **0** | 3 | 0 | 25% | #DIV/0! |
| 7 | 15 | ពោធិសាត់ | 49 | 63 | 43 | 33 | **2** | 38 | **2** | 1 | 0 | 3% | 0% |
| 8 | 2 | បាត់ដំបង | 102 | 103 | 58 | 13 | **0** | 47 | **0** | 0 | 0 | 0% | #DIV/0! |
| 9 | 7 | កំពត | 93 | 101 | 84 | 72 | **0** | 38 | **0** | 0 | 0 | 0% | #DIV/0! |
| 10 | 9 | កោះកុង | 29 | 36 | 28 | 4 | **0** | 28 | **0** | 6 | 0 | 21% | #DIV/0! |
| 11 | 18 | ព្រះសីហនុ | 27 | 36 | 29 | 28 | **0** | 21 | **0** | 0 | 0 | 0% | #DIV/0! |
| 12 | 23 | កែប | 5 | 6 | 6 | 6 | **0** | 6 | **0** | 0 | 0 | 0% | #DIV/0! |
| 13 | 13 | ព្រះវិហារ | 51 | 51 | 40 | 40 | **6** | 40 | **6** | 0 | 0 | 0% | 0% |
| 14 | 10 | ក្រចេះ | 46 | 46 | 25 | 27 | **12** | 25 | **12** | 5 | 3 | 20% | 25% |
| 15 | 3 | កំពង់ចាម | 173 | 189 | 18 | 48 | **1** | 18 | **1** | 9 | 0 | 50% | 0% |
| 16 | 6 | កំពង់ធំ | 81 | 88 | 59 | 47 | **6** | 46 | **6** | 0 | 0 | 0% | 0% |
| 17 | 11 | មណ្ឌលគិរី | 21 | 19 | 12 | 1 | **17** | 12 | **17** | 4 | 5 | 33% | 29% |
| 18 | 16 | រតនគិរី | 50 | 59 | 56 | 46 | **50** | 32 | **50** | 0 | 0 | 0% | 0% |
| 19 | 19 | ស្ទឹងត្រែង | 34 | 37 | 33 | 20 | **11** | 24 | **11** | 2 | 0 | 8% | 0% |
| 20 | 17 | សៀមរាប | 100 | 111 | 75 | 28 | **0** | 72 | **0** | 10 | 0 | 14% | #DIV/0! |
| 21 | 1 | បន្ទាយមានជ័យ | 65 | 66 | 22 | 10 | **0** | 22 | **0** | 2 | 0 | 9% | #DIV/0! |
| 22 | 22 | ឧត្តរមានជ័យ | 24 | 25 | 24 | 5 | **0** | 22 | **0** | 2 | 0 | 9% | #DIV/0! |
| 23 | 24 | ប៉ៃលិន | 8 | 9 | 9 | 6 | **0** | 9 | **0** | 7 | 0 | 78% | #DIV/0! |
| | | **សរុប** | **1537** | **1665** | **697** | **748** | **105** | **564** | **105** | **92** | 8 | 16% | 8% |